**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

# <u>សារថ្វាយព្រះពរ</u>

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះករុណាព្រះមហាក្សត្រ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** !

ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សាព្រះករុណា គម្រប់ **៦២** យាងចូល **៦៣** ព្រះវស្សា នាថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០១៥ ខាងមុខនេះ ទូលព្រះបង្គំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្នុងនាមទូលព្រះបង្គំផ្ទាល់ មានបីតិសោមនស្សរីករាយ សូមថ្វាយព្រះសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនាដ៏មហាប្រសើរថ្វាយចំពោះ **ព្រះករុណា ព្រះមហាក្សត្រ** សូមព្រះអង្គប្រកបដោយ ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះប្រាជ្ញាស្មារតីឈ្លាសវៃ ព្រះជន្មាយុយឺនយូរ ដើម្បីគង់នៅគ្រងព្រះបរមរាជសម្បត្តិបន្តទៅទៀត។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ **ព្រះករុណា** ដែលព្រះអង្គតែងយកព្រះរាជហឫទ័យទុកដាក់ក្នុងវិស័យមនុស្សធម៌ វប្បធម៌ អប់រំ សង្គមកិច្ច ព្រះពុទ្ធសាសនា កិច្ចការបរទេស និងជីវភាពរស់នៅរបស់ប្រជាជនជាទីស្នេហាបំផុត និងជាពិសេសសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ។

ទូលព្រះបង្គំសូមលើកហត្ថប្រណម្យបួងសួងដល់ទេវតាឆ្នាំថ្មីឆ្នាំមមែ គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក និងដួងព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ តាមជួយអភិបាលប្រោសព្រំព្រះសព្ទសាធុការពរជ័យគ្រប់ប្រការថ្វាយ **ព្រះករុណា ព្រះមហាក្សត្រ** សូមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥

**ប្រាក់ សុខុន**
**រដ្ឋមន្ត្រី និងជាតំណាងមន្ត្រីរាជការគ្រប់ថ្នាក់នៃ**
**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**